**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

# អត្ថបទសារព័ត៌មាន

AIA.COM.KH

## ក្ដីសុបិនរបស់ម្ចាស់ជើងឯក AIA Corporate Cup 2025 បានក្លាយជាពិតនៅកីឡដ្ឋាន Tottenham Hotspur ទីក្រុងឡុងដ៍

*ក្រុមបាល់ទាត់បុរសសាលាអន្តរជាតិ CIA FIRST ដែលជាម្ចាស់ជើងឯក AIA Corporate Cup 2025 បានធ្វើដំណើរត្រលប់មកកម្ពុជាវិញជាមួយមោទនភាព និងអនុស្សាវរីយ៍មិនអាចបំភ្លេចបានបន្ទាប់ពីតំណាងឱ្យ អេ អាយ អេ ខេមបូឌា ក្នុងការប្រកួតដណ្ដើមជើងឯក Grand Finals ដែលធ្វើឡើងផ្ទាល់នៅកីឡដ្ឋាន Tottenham Hotspur (Spurs) កាលពីថ្ងៃចន្ទ ទី12 ខែឧសភា។*

ការប្រកួតវគ្គផ្ដាច់ព្រ័ត្រឆ្នាំនេះឃើញមានអ្នកចូលរួមជាង 70 នាក់មកពី AIA តាមបណ្ដាប្រទេសនានាចំនួន 5 ដែលក្នុងការប្រកួតនីមួយៗបានបង្ហាញពីការងារជាក្រុម ភាពរួសរាយរាក់ទាក់ និងសាមគ្គីភាពជាមួយបណ្ដាជាតិសាសន៍ទៃ។ សូមបញ្ជាក់ផងដែរថា នេះជាលើកដំបូងចាប់តាំងពីការបើកសម្ពោធជាផ្លូវការនៅឆ្នាំ 2019 ដែលកីឡដ្ឋាន Tottenham Hotspur បើកឱ្យមានព្រឹត្តិការណ៍បែបនេះ ដើម្បីបន្ថែមភាព រំភើបរីករាយ និង ពិតជាកិត្តិយសរបស់កីឡាករដែលបានប្រកួតផ្ទាល់លើវាលស្មៅដែលសម្រាប់ប្រកួត English Premier League។

កម្មវិធីប្រកួតបាល់ទាត់នេះរៀបចំឡើងក្នុងទម្រង់ម្នាង 5នាក់ ដែលមាន 22ប្រកួត។ ក្រុមបាល់ទាត់បុរស CIA FIRST បានបង្ហាញភាពស្ទាហាប់  និងប្រឹងប្រែងទោះបីជាបានឡើងត្រឹមវគ្គពាក់កណ្ដាលផ្ដាច់ព្រ័ត្រដោយបានចាញ់ស៊ុតបាល់ប៉េណាល់ទីដ៏តានតឹងក៏ដោយ។ ទោះបីជាលទ្ធផលយ៉ាងនេះក្ដី សមាជិកក្រុមនីមួយៗបានត្រលប់មកវិញជាមួយនឹងអនុស្សាវរីយ៍មិនអាចកាត់ថ្លៃបានអស់មួយជីវិត។

បន្ថែមអត្ថន័យពីលើបទពិសោធប្រកួតលើវាលស្មៅរាបស្មើដូចព្រំរបស់កីឡដ្ឋាន Tottenham Hotspur ក្រុមកីឡាកររបស់ CIA FIRST ក៏ត្រូវបានអញ្ជើញចូលរួមទស្សនាការប្រកួត English Premier League ក្នុងទឹកដីរបស់ Spurs ដែលលេងទល់នឹង Crystal Palace។ នាកម្មវិធីនោះ ពួកគេក៏ទទួលបាននូវបទពិសោធថ្មីសន្ធាងដ៏រំភើបប្លែកអារម្មណ៍មួយទៀត នោះគឺការប្រណាំងឡាន F1 Drive នៅកីឡដ្ឋាន Spurs។

លោក Matthew ប្រធានក្រុមបាល់ទាត់បុរស CIA FIRST បានចែករំលែកថា៖

"វាជាកិត្តិយសដ៏ធំធេងក្នុងនាមជាប្រធានក្រុម និងតំណាងឱ្យ អេ អាយ អេ ខេមបូឌា ទៅប្រកួតក្នុងកម្មវិធីដ៏ធំពិសេសបែបនេះ។ ឱកាសបានទៅប្រកួតនៅកីឡដ្ឋាន Tottenham Hotspur និងបានផ្សារភ្ជាប់ចំណងមិត្តភាពជាមួយនឹងក្រុមមកពីបណ្ដាប្រទេសផ្សេងពិតជាបង្កើតបាននូវអនុស្សាវរីយ៍ដ៏អស្ចារ្យមិនអាចបំភ្លេចបាន។ ការប្រកួតបាល់ទាត់ វាលើសពីការចាញ់-ឈ្នះ ប៉ុន្តែវាឆ្លុះបញ្ចាំងអំពីមិត្តភាព ការតស៊ូ

ការប្តេជ្ញា និងមោទនភាព។ ឆ្លៀតក្នុងពេលនេះ ខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អេ អាយ អេ ខេមបូឌា ចំពោះការរៀបចំ និងរ៉ាប់រងទាំងស្រុងលើការធ្វើដំណើររបស់យើងទាំងអស់គ្នា។ អ្វីដែលយើងខ្ញុំទទួលបាននេះ ពិតជាបទពិសោធដែលមិនអាចកាត់ថ្លៃបាន។ ខ្ញុំគិតថាបទពិសោធបែបនេះ មានតែ អេ អាយ អេ ប៉ុណ្ណោះដែលអាចផ្តល់ជូនបាន។”

សូមបញ្ជាក់ផងដែរថា ពានរង្វាន់បាល់ទាត់ AIA Corporate Cup 2025 គឺជាការប្រកួតលើកទី 2 សម្រាប់អតិថិជនសាជីវកម្មរបស់ អេ អាយ អេ ខេមបូឌា ដែលបានរៀបចំឡើងចាប់ពីខែ វិច្ឆិកា ឆ្នាំ 2024 ដល់ខែមករា ឆ្នាំ 2025 ដែលក្រុមបាល់ទាត់មកពី CIA FIRST បានក្លាយជាជើងឯកបន្ទាប់ពីបានប្រកួតប្រជែងជាមួយនឹងក្រុមសាជីវកម្មចំនួន 27 ផ្សេងទៀត។

អ្វីដែលជើងឯក AIA Corporate Cup គឺជាបទពិសោធល្អឥតខ្ចោះមិនអាចកាត់ថ្លៃបាន ដែលបង្ហាញពីការប្តេជ្ញារបស់ អេ អាយ អេ លើការផ្តល់ជូនលើសពីដំណោះស្រាយសេវាធានារ៉ាប់ រងអាយុជីវិត និងសុខភាពនាំមុខគេ ដោយរួមបញ្ចូលទាំងគំនិតផ្តួចផ្តើមដើម្បីអតិថិជនរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។

AIA Corporate Cup ក៏មានគោលបំណងលើកកម្ពស់សុខភាព និងសុខុមាលភាពរបស់អតិថិជនសាជីវកម្មរបស់ អេ អាយ អេ ខេមបូឌា។ វាក៏ជំរុញទំនាក់ទំនងកាន់តែរឹងមាំរវាងកីឡាករចូលរួម លើកទឹកចិត្តឱ្យចាប់យកទម្លាប់រស់មានសុខភាពល្អ។

គំនិតផ្តួចផ្តើមនេះ គឺជាផ្នែកមួយនៃកម្មវិធី WorkWell with AIA ដោយផ្តោតលើកត្តាចម្បងធំៗ 4 ដែលបានបង្កើតឡើងយ៉ាងពិសេស ដើម្បីជានាថានិយោជក និងនិយោជិតរីករាយទទួលយកបទពិសោធនៃអត្ថប្រយោជន៍រួមលើផ្នែកសុខភាព និងសុខមាលភាព រួមមាន Live Well (រស់នៅល្អ ដោយផ្តោតលើសុខុមាលភាពរាងកាយ) Think Well (គិតល្អ ដោយផ្តោតលើសុខុមាលភាពផ្លូវចិត្ត) Plan Well (ផែនការល្អ ដោយផ្តោតលើសុខុមាលភាពហិរញ្ញវត្ថុ) និង Feel Well (អារម្មណ៍ល្អ ដោយផ្តោតលើសុខុមាលភាពសង្គម)។

កម្មវិធីនេះក៏ស្របតាមគោលបំណងរបស់ អេ អាយ អេ ខេមបូឌា ក្នុងការជួយប្រជាជនកម្ពុជាឱ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ ក៏ដូចជាគាំទ្រគំនិតផ្តួចផ្តើម AIA One Billion របស់ AIA Group ដែលមានគោលបំណងដូចគ្នា ក្នុងការជួយប្រជាជនមួយពាន់លាននាក់នៅអាស៊ីឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរនៅឆ្នាំ 2030។

ស្វែងយល់អំពី AIA Corporate Cup តាមរយៈកម្មវិធី WorkWell With AIA | អេ អាយ អេ ខេមបូឌា ឬចូលក្នុងគ្រុបហ្វេសប៊ុក Wellness@Work តាមរយៈ https://rb.gy/afoly9 ។

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

# អត្ថបទសារព័ត៌មាន

AIA.COM.KH

ព័ត៌មានលម្អិតលើការទទួលយកដំណោះស្រាយការការពារលោកអ្នក និងគ្រួសារពី អេ អាយ អេ ខេមបូឌា លើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ និងការធានារ៉ាប់រងសុខភាពជាក្រុម សូមទាក់ទង AIA Client Care តាមរយៈលេខ 086 999 242 ឬចូលទៅកាន់គេហទំព័រ aia.com.kh។

## អំពី អេ អាយ អេ ខេមបូឌា

*ក្រុមហ៊ុនធានារ៉ាប់រង អេ អាយ អេ ខេមបូឌា គឺជាបុត្រសម្ព័ន្ធនៃ AIA Group មានក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅទូទាំងតំបន់អាស៊ីដែលស្ថិតក្នុងបញ្ជីឈ្មោះសាធារណៈឯករាជ្យធំជាងគេ។ ក្រុមហ៊ុនមានវត្តមាននៅលើទីផ្សារចំនួន 18 ប្រទេសនៅអាស៊ីប៉ាស៊ីហ្វិក - សាខាគ្រប់គ្រងទាំងស្រុង។*

*ចាប់តាំងពីបើកដំណើរការនៅកម្ពុជា រាល់សកម្មភាពរបស់ អេ អាយ អេ ខេមបូឌា ធ្វើឡើងស្របតាមគោលបំណង ក្នុងការជួយឲ្យប្រជាជនកម្ពុជាឲ្យរស់នៅមានសុខភាព និងជីវិតកាន់តែប្រសើរ។ ចាប់តាំងពីចាប់ផ្តើមអាជីវកម្មក្នុងឆ្នាំ 2017 យើងបានក្លាយជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពដំបូងបង្អស់នៅកម្ពុជាផ្តល់ការការពាររហូតដល់ 26 ស្ថានភាពជំងឺធ្ងន់ធ្ងរ។ ហើយបច្ចុប្បន្ននេះ អេ អាយ អេ អខេមបូឌា ក៏បានពង្រីកការការពារថ្មីចំពោះជំងឺធ្ងន់ធ្ងរលើលក្ខខណ្ឌរហូតដល់ 118 ចាប់ពីដំណាក់កាលដំបូងរហូតដល់ដំណាក់កាលចុងក្រោយដើម្បីរក្សាជំហរជាក្រុមហ៊ុនដំបូងបង្អស់នៅវិស័យធានារ៉ាប់រងកម្ពុជា។*

*ក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រងឈានមុខគេមួយនៅកម្ពុជា  អេ អាយ អេ ខេមបូឌា ផ្តល់ជូននូវដំណោះស្រាយជីវិតឈានមុខគេនៅលើទីផ្សារសម្រាប់ប្រជាជនកម្ពុជាគ្រប់មជ្ឈដ្ឋាន រាប់ចាប់ពីគម្រោងធានារ៉ាប់រងសំខាន់ៗដែលបង្កើតឡើងស្របតាមតម្រូវការជាក់លាក់ ដែលរួមមានគម្រោងការពារលើជំងឺធ្ងន់ធ្ងរ គ្រោះថ្នាក់ចៃដន្យ ថ្លៃសម្រួលការសម្រាកព្យាបាលនៅមន្ទីរពេទ្យ និងជំនួយសង្គ្រោះបន្ទាន់នៅក្រៅប្រទេស។*

*អេ អាយ អេ ខេមបូឌា ផ្តោតសំខាន់លើការណែនាំ និងជម្រុញឲ្យប្រជាជនក្នុងសង្គមទទួលយកទម្លាប់ល្អៗ ក៏ដូចជាមធ្យោបាយដើម្បីឲ្យពួកគាត់ទទួលបាននូវសុខភាពល្អ តាមរយៈគំនិតផ្តួចផ្តើម រួមមានកិច្ចសហការជាមួយក្រសួងកិច្ចការនារី ដើម្បីពង្រឹងលើសមភាពយេនឌ័រនិងសិទ្ធិស្ត្រី ការលើកកម្ពស់ការយល់ដឹងអំពីជំងឺមហារីកសុដន់ តាមរយៈយុទ្ធនាការប្រចាំឆ្នាំ AIA Fit for Hope របស់យើងជាដើម។*

*យើងក៏ចូលរួមជួយលើកស្ទួយកុមារដែលជួបបញ្ហាជីវភាពរាប់ពាន់នាក់ផងដែរ ដោយតាមរយៈឧបត្ថម្ភដល់លីគបាល់ទាត់ AIA-ISF ដែលជាលីគបាល់ទាត់ថ្នាក់មូលដ្ឋានធំជាងគេនៅកម្ពុជា។ ជាងនេះទៀតសោធ យើងក៏សហការជាមួយក្លិបTottenham Hotspur ក្នុងក្របខណ្ឌ English Premier League ដែលជាដៃគូសកល និងជាក្លិបបាល់ទាត់កំពូលនៅលើពិភពលោក ដើម្បីធានាថាកុមារទាំងនោះទទួលបានការអប់រំដែលពួកគេសមនឹងទទួលបាន។*

**អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក**

អគារ ជីអាយអេ ថៅអឺរ ជាន់ទី៣១ ផ្លូវសុភមង្គល ភូមិ១៤ សង្កាត់
ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

លេខទូរស័ព្ទ៖ (855) 86 999 242

**អត្ថបទសារព័ត៌មាន**

AIA.COM.KH

*អេ អាយ អេ ខេមបូឌា គឺជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងសុខភាពកម្ពុជាតែមួយគត់ដែលបានទទួលពានរង្វាន់ "ក្រុមហ៊ុនល្អបំផុតសម្រាប់ការងារនៅអាស៊ី (Best Companies to Work for in Asia)" ពី HR Asia ក្នុងរយៈពេល 5ឆ្នាំជាប់គ្នាពី 2020 ដល់ 2024 អេ អាយ អេ ខេមបូឌា មានការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ និងបច្ចុប្បន្នបានពង្រីកសាខានៅខេត្តសៀមរាប កំពត កំពង់ចាម និងបាត់ដំបង។*

-------------------

ទំនាក់ទំនងសារព័ត៌មាន

**រ៉េន ពិសាល**

ប្រធានផ្នែកទំនាក់ទំនងសាជីវកម្ម

អេ អាយ អេ (ខេមបូឌា) ឡាយហ្វ៍ អ៊ិនសួរេន ម.ក

pisal-p.ren@aia.com